ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៧៨
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០០
សាលដីកា
លេខៈ ៣០០
ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ......... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម
លោក ............... ចៅក្រមរបាយការណ៍(អវត្តមាន)

ក្រឡាបញ្ជី
-លោក ..............

តំណាងមហាអយ្យការ
-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៤៩(ធ) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣១៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ មសណ ជាចុងបណ្តឹងសាទុក្ខ ភេទស្រី អាយុ៧៩ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ី ជរា ទីលំនៅសព្វថ្ងៃក្រុមទី១៤ ភូមិបឹងកុក ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ឪពុកឈ្មោះស្រេង(ស)ម្តាយឈ្មោះ នាង(ស) ។

និងចុងចម្លើយឈ្មោះ**យស** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិថ្នល់បំបែក ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ស៊ាង យុន(ស) ម្តាយឈ្មោះ ណយ ហៀក(រ) ។

មានមេធាវីឈ្មោះ............... ។

តតិយជនឈ្មោះ ប៉ាក់ ង៉ាក់ ភេទប្រុសអាយុ ៣៤ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិទី៧ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

ឪពុកឈ្មោះ ហុង ហេង (រ) ម្តាយឈ្មោះ ហ៊ុយ ខេង (រ)។

**កម្មវត្ថុបណ្តឹងៈ** ប្តឹងទារប្រាក់ ៩.០០០ដុល្លារអាមេរិក

បានឃើញបណ្តឹងសាទុក្ខលេខ២០៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះយស ប្តឹងមិនសុខចិត្តពីសាលដីកាលេខ៤៩(ធ)ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០ របស់សាលាឧទ្ធរណ៍ លើចំណុចនៃសេចក្តីសម្រេចទាំងមូល

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៧៨ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧ខែកញ្ញាឆ្នាំ១៩៩៨ របស់ឈ្មោះតែ ឈុនឡាង និងឈ្មោះមសណាប្តឹងទារប្រាក់ចំនួន ៩០០០ដុល្លាអាមេរិក ពីឈ្មោះយស ប្រពន្ធឈ្មោះ ហាក់ សុខម៉េង ដោយអាងហេតុថា ឈ្មោះនេះរួមជាមួយនឹងប្រពន្ធបានទិញរថយន្តដឹកឈើម៉ាកម៉ាសកាណុងចំនួន៣គ្រឿងពីខ្លួនក្នុងតម្លៃ១៨០០០ដុល្លាអាមេរិក ដោយបានធ្វើកិច្ចសន្យាជាលាយលក្ខអក្សរត្រឹមត្រូវហើយបានប្រគល់ប្រាក់ថ្លៃទិញជាបន្តបន្ទាប់សរុបបាន ៩០០០ដុល្លា នៅខ្វះចំនួន ៩០០០ដុល្លាទៀត មិនព្រមសងរហូតទល់សព្វថ្ងៃ ។

បានឃើញពាក្យបណ្តឹងរបស់ឈ្មោះ ប៉ាក់ ង៉ាក់ ចុះថ្ងៃទី០៨ ខែធ្នូឆ្នាំ១៩៩៨ ប្តឹងសុំចូលជាតតិយជនក្នុងរឿងក្តីនេះ ដើម្បីទាមទារយករថយន្តម៉ាកម៉ាសកាណុងពីគ្រឿង ដែលតុលាកាបានរឹបអូសពីឈ្មោះយស ឬទាមទារយកប្រាក់បានមកពីការលក់ឡាយឡុងរថយន្តនោះ ដោយអាងហេតុថា រថយន្តទាំងពីគ្រឿងនេះជាកម្មសិទ្ធិរបស់ឈ្មោះ ហាក់ យឹម ហើយហាក់ យឹម ជាកូនបំណុលរបស់ខ្លួនតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ៧៥(ក) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៨ ឥឡូវនេះឈ្មោះ តែ ឈុនឡេង បែរជាអះអាងថា ជាឡានកម្មសិទ្ធិរបស់គាត់ ហើយគាត់បានលក់ឲ្យទៅឈ្មោះ យស ។

បានឃើញសាលក្រមលេខ ១៨៨(ក) ចុះថ្ងៃទី៣០ ខែធ្នូឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាមដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅះ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះតែ ឈុនឡាង និងឈ្មោះ មសណាចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់និងគតិច្បាប់ ។

២-ទទួលស្គាល់កិច្ចសន្យាទិញ លក់រថយន្ត ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៧ រវាងអ្នកទិញឈ្មោះ យស និងនាង ហាក់ សុខម៉េង និងអ្នកលក់ឈ្មោះ តែ ឈុនឡេង មសណាទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។(តាមមាត្រា ៣ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៣-ទទួលពាក្យបណ្តឹងរបស់តតិយជនឈ្មោះប៉ាក់ ង៉ាក់ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៤-ឲ្យឈ្មោះ យស និងប្រពន្ធឈ្មោះ ហាក់ សុខម៉េង សងប្រាក់ចំនួន ៧៥០០ដុល្លា ឲ្យទៅឈ្មោះ មសណានិងឈ្មោះតែ ឈុនឡាង ។ក្នុងនោះតុលាការត្រូវប្រគល់ថ្លៃលក់រថយន្តកាណុងពីគ្រឿងស្មើនឹងចំនួន៥០៥០ដុល្លាឲ្យទៅឈ្មោះមសណាតែ ឈុនឡាង ។ ឯប្រាក់នៅសល់ចំនួន ២៤៥០ដុល្លា ទៀតរងចាំពេលសាលក្រមចូលជាស្ថាពរ ។(តាមមាត្រា២២ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៥-នៅពេលសាលក្រមចូលជាស្ថាពរ បើឈ្មោះយស និងប្រពន្ធឈ្មោះ ហាក់ សុខម៉េង គ្មានប្រាក់សងទេ តុលាការនឹងរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុរបស់ឈ្មោះយស និងប្រពន្ធឈ្មោះ ហាក់ សុខម៉េង លក់ឡាយឡុងដើម្បីសងប្រាក់ទៅម្ចាស់បំណុល(តាមមាត្រា២៤,៣១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧០០០៖ ពីដើមចោទ និង២០០០៖ ពីតតិយជនចុងចម្លើយដែលប្រាក់នេះភាគី បានបង់ទ្បួចហើយ ។នៅពេលសាលក្រមចូលជាស្ថាពរ បង្គាប់ឲ្យចុងចម្លើយបង់សងធទៅឲ្យដើមចោទវិញ និងឲ្យបង់ ពន្ធសមាមាត្រ១% នៃប្រាក់៧៥០០ដុល្លា បន្ថែមទៀត ។ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០%និងបានជារង្វាន់ក្រឡាបញ្ជី ទូទាំងប្រទេស២០%។ប្រាក់នេះតម្រូវឲ្យដើមចោទបង់ជាមុនដែរ ។

៧-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងចុងចម្លើយ ព្រមទាំងចំពោះមុខតតិយជន ដោយទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ យុន ស៊ា និងឈ្មោះ ប៉ាក់ ង៉ាក់ ចុះថ្ងៃទី១៥ ខែកុម្ភៈ១៩៩៩ ប្តឹង មិន សុខចិត្តលើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ៤៩(ធ) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ឈ្មោះយស និងប៉ាក់ ង៉ាក់ ទុកជាត្រឹមត្រូវតាម ទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ១៨៨(ក) ចុះថ្ងៃទី៣០ខែធ្នូឆ្នាំ១៩៩៨ របស់តុលាការខេត្ត កំពង់ចាម ទុកជាបានការ ទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៖ រង្វាន់ក្រឡាបញ្ជីកាន់ ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ចំនួន ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខ ចុងចម្លើយ ។ បើកផ្លូវប្តឹង ទាស់និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២០៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះយស ស្ថិតក្នុងកំណត់ ច្បាប់ ។

បានឃើញសារណារបស់ឈ្មោះ យស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០០ ។

បានឃើញសារណាតបរបស់ឈ្មោះ មសណចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០១ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះ បាន ។ សាលដីការបស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះយស (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះឆ្លើយថា:

-ខ្លួនទិញឡាននេះ ៣គ្រឿង ដល់ប្រើប្រាស់បានតែ ២គ្រឿង ។ ១គ្រឿងទៀតខ្លួនលក់ យកលុយមកជួសជុលពីរគ្រឿងនេះ ។ ក្នុងការទិញនេះខ្លួនឱ្យលុយបាន១០.៥០០ដុល្លា ទៅពេលខ្លួនប្រគល់ លុយជិតគ្រប់ ស្រាប់តែឈ្មោះប៉ាក់ ង៉ាក់ ក៏គាត់ត្រូវតែទារលុយពីខ្លួនដែរ ដូច្នេះខ្លួក៏ឈប់ឲ្យលុយទៅដើមចោទ ។ខ្លួនប្រើឡានបានពីរឆ្នាំ ដើមចោទប្តឹងរឹបអូសឡានចូលតុលាការ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ម៉ៅ ស្រេងលាយ ។

មេធាវីរបស់ចុងចម្លើយធ្វើសេចក្តីសន្និដ្ឋានថា:

-ដើមចោទលក់ឡានឱ្យកូនក្តីខ្លួនៗបង់បាន១០.៥០០ដុល្លា ស្រាប់តែឈ្មោះប៉ាក់ ងាក់ មកទាំលុយពីកូនក្តីខ្លួនទៀត ដោយសំអាងថា កាតគ្រីមិនមែនជាឈ្មោះរបស់ដើមចោទ ដូច្នេះដើមចោទយកឡានរបស់អ្នកដទៃមកលក់ឱ្យកូនក្តីខ្លួន ដូច្នេះហើយកូនក្តីខ្លួនក៏ឈប់ឱ្យ

**សំណូមពរ**

.សុំបដិសេធសាលក្រម និងសាលដីការបស់សាលាឧទ្ធរណ៍ ។

.បដិសេធកិច្ចសន្យាទិញ-លក់រថយន្តនោះចោល ។

-ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោកឃុនស៊ាសារណារបស់ដើមចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០ របស់លោក ឃស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ។

-យល់ឃើញថា តាមកំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី ១០ខែកញ្ញា ឆ្នាំ១៩៩៨ នៅតុលាការខេត្តកំពង់ចាមក្នុងចម្លើយលោក ឃស ទទួលស្គាល់ថា ខ្លួននៅជំពាក់ប្រាក់ដើមចោទតែ៧.៥០០ដុល្លា ថ្លៃទិញរថយន្តម៉ាកម៉ាសកាណុងចំនួន ៣គ្រឿង ដូច្នេះឈ្មោះនេះមានកាតព្វកិច្ចសងបំណុល នេះទៅដើមចោទតាមការកំណត់នៃមាត្រា២៩ នៃក្រឹត្យ-ច្បាប់លេខ ៣៨ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា ការដែលចុងចម្លើយក៏ដូចមេធាវីរបស់លោកដែរ ដែលលើកឡើងនាសវនាការនេះអំពីភាពមិនប្រក្រតីនៃការលក់-ទិញរថយន្តនេះ ដែលមានពាក់ព័ន្ធដល់តតិយជននោះ តុលាការកំពូលពុំអាចពិចារណាបានទេពីព្រោះតតិយជនបានចូលមកក្នុងរឿងក្តីនេះហើយៗក៏ពុំបានប្តឹង សាទុក្ខដែរទេ ។

-យល់ឃើញថា ដើមចោទបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូល រួចហើយ ប៉ុន្តែពុំបានចូលរួមនាពេលសវនាការនេះទេ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៩(ធ) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយលោកយស**

**កំបាំងមុខដើមចោទអ្នកស្រី មសណាប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ២០៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០ របស់លោក យស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៩(ធ) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី មសណាបានបង់គឺ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់១៩០០០រៀល ទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តកំពង់ចាម ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ ។